**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤៣ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលក្រឡាផ្ទៃដីតំបន់អភិវឌ្ឍន៍ បឹងកក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្រ្តី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការប្រកាសឱ្យ ប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨ ស្តីពីការធ្វើអនុបយោគ
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១០ ស្តីពីការធ្វើអនុបយោគដីតំបន់ អភិវឌ្ឍន៍បឹងកក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- យោងលិខិតលេខ ៣២១ លស.ពស១.ក្រ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១០ របស់សាលារាជធានីភ្នំពេញ
- យោងលិខិតលេខ ៧០៩ ដនសស.បទ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ
- យោងប្លង់កែសំរួលព្រំប្រទល់តំបន់អភិវឌ្ឍន៍បឹងកក់ និងតារាងនិយាមការ ចុះថ្ងៃទី១០ខែសីហាឆ្នាំ ២០១១ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ។

## សម្រេច

**មាត្រា ១.-**

ដីសាធារណៈរបស់រដ្ឋ ដែលស្ថិតនៅតំបន់បឹងកក់ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ហើយបានធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១០ ត្រូវបានបែងចែកដូចខាងក្រោម៖

១. ដីទំហំ **១១៤,៤១** ហិកតា ដូចមានផែនទីកំណត់ព្រំប្រទល់ដែលមាននិយាមកា ភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ សម្រាប់ជូនក្រុមហ៊ុន ស៊ូកាគូអ៊ីន ធ្វើការអភិវឌ្ឍន៍ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងប្លង់គោលអភិវឌ្ឍន៍តំបន់បឹងកក់ ភ្ជាប់ជាឧបសម្ព័ន្ធទី២ ។

២. ដីទំហំដី **១២,៤៤** ហិកតា ដូចមានផែនទីកំណត់ព្រំប្រទល់ដែលមាននិយាមកា ភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ រាជរដ្ឋាភិបាលផ្តល់ជាប្រទានកម្មជូនប្រជាពលរដ្ឋ ដោយរដ្ឋទទួលបន្ទុកបង់ពន្ធប្រថាប់ត្រាជំនួស ។

**មាត្រា ២.-**

ផ្ទៃដី **១១៤,៤១** ហិកតា និង **១២,៤៤** ហិកតា ខាងលើនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែង និងបំពេញនីតិវិធីអនុវត្ត ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាលារាជធានីភ្នំពេញ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១១... ខែ.សីហា...ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ